# របាយការណ៍វេទិកាពិភាក្សា
# ស្តីពី
# "ការចុះអនុសារណៈយោគយល់រវាងរដ្ឋាភិបាល និង សង្គមស៊ីវិល ដើម្បីឆ្លើយតបទៅនិងបញ្ហាអេដស៍នៅកម្ពុជា"
## សណ្ឋាគារ សាន់ វេ
## ថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០១០

១. សេចក្តីផ្តើម

គណៈកម្មាធិការសម្របសម្រួលប្រយុទ្ធនឹងជំងឺអេដស៍ (គសអ) គឺជាបណ្តាញអង្គការសង្គមស៊ីវិលកំពុងធ្វើការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅកម្ពុជា។ គសអ បង្កើតបាន១៦ឆ្នាំ ក្នុងកំឡុងពេលនេះ គសអ បាននឹងកំពុងក្លាយជាបណ្តាញមួយដែលរឹងមាំ និងទទួលស្គាល់ដោយថ្នាក់ជាតិថា ជាតួអង្គសម្របសម្រួលរវាងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល ដែលធ្វើការលើមេរោគអេដស៍ និងជំងឺអេដស៍ នៅកម្ពុជា។ ការទទួលខុសត្រូវចំបងរបស់ គសអ គឺៈការសម្របសម្រួល និងចែករំលែកព័ត៌មានរវាងសង្គមស៊ីវិលទាំងថ្នាក់ជាតិ អន្តរជាតិ និងថ្នាក់តំបន់ តស៊ូមតិ ភាពជាតំណាង បណ្តុះបណ្តាល និងរៀបចំយុទ្ធនាការអប់រំ។ គសអ ធ្វើការគាំទ្រដល់បទអន្តរាគមន៍នានារបស់សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធជាសំខាន់ ដើម្បីបង្កើតឲ្យមានបរិយាកាសល្អឆ្ពោះទៅសម្រេចគោលដៅការទទួលបានសេវាជាសកល គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ គោលដៅមហាសន្និបាតអង្គការសហប្រជាជាតិស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ និងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយនិងពហុវិស័យដើម្បីឆ្លើយតបទៅនិងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៣។

អនុសារណៈយោគយល់រវាងរដ្ឋាភិបាលនិងសង្គមស៊ីវិលគឺជាដំណើរការនៃការទទួលបាននូវសិទ្ធិ រឺការអនុញ្ញាតពីរដ្ឋាភិបាល ជាពិសេសក្រសួងពាក់ព័ន្ធ មុនពេលចាប់អនុវត្តការងារ។ យោងលើរបាយការណ៍របស់អង្គការដែលធ្វើការងារនៅថ្នាក់សហគមន៍បានបញ្ជាក់ថា បញ្ហាដែលជួបប្រទះញឹកញាប់ជាងគេនោះគឺៈ ចំណាយពេលវេលាច្រើនក្នុងដំណើរការចុះអនុសារណៈយោគយល់រវាងរដ្ឋាភិបាលនិងសង្គមស៊ីវិល ការបំពេញទម្រង់សុំញ៉ាំដ៏ច្រើន គ្មានគោលការណ៍ណែនាំ និងមានលក្ខ័ខ័ណ្ឌតម្រូវច្រើនសម្រាប់ក្រសួងផ្សេងគ្នា ទម្រង់ផ្សេងគ្នា និង ខ្សែបណ្តោយក្រសួងនីមួយៗផងដែរ។

ដោយមានការគាំទ្រមូលនិធិពីអង្គការខាណា គសអ បានរៀបចំនូវវេទិកាពិភាក្សាមួយរវាងរដ្ឋាភិបាលនិងសង្គមស៊ីវិលនៅសណ្ឋាគារ សាន់ វេ កាលពីថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០១០ ក្នុងគោលបំណងស្វែងរកនូវមធ្យោបាយដ៏មានប្រសិទ្ធភាពសម្រាប់សង្គមស៊ីវិលធ្វើការងារឲ្យបានងាយស្រួលនៅតាមសហគមន៍និងកាត់បន្ថយចំនួននៃអនុសារណៈយោគយល់រវាងរដ្ឋាភិបាលនិងសង្គមស៊ីវិល។ អ្នកចូលរួមក្នុងកិច្ចពិភាក្សានេះមានចំនួន៧៩នាក់ ស្រីចំនួន ២៧នាក់ ដែលមកពីស្ថាប័ននានា។ សូមមើលបញ្ជីឈ្មោះលម្អិតនៅក្នុងឧបសម្ព័ន្ធ ១ ។

របៀបវារៈ

- សុន្ទរកថាស្វាគមន៍ដោយតំណាងសង្គមស៊ីវិល
- បទបង្ហាញស្តីពីឧបសគ្គនៃ ដំណើរការចុះអនុសារណៈយោគយល់រវាងរដ្ឋាភិបាលនិងសង្គមស៊ីវិល
- កិច្ចពិភាក្សាពេញអង្គ
- ផែនការបន្ទាប់

**២. ដំណើរការនៃកិច្ចពិភាក្សា**

លោក ទឹម វ៉ា នាយកប្រតិបត្តិ គសអ បានស្វាគមន៍ និងសម្តែងនូវការកោតសរសើរ ដល់វាគ្មិននិងអ្នកចូលរួមទាំងអស់ ដែលបានចូលរួមដើម្បីពិភាក្សាអំពីស្ថានភាពថ្មីៗស្តីពីការចុះ អនុសារណៈយោគយល់រវាងរដ្ឋាភិបាលនិងសង្គមស៊ីវិល។ លោក ទឹម វ៉ា បានបញ្ជាក់ថា វេទិកាពិភាក្សានេះមានគោលបំណង៖ ទី១ ដើម្បីពង្រឹងការយោគយល់គ្នារវាងសង្គមស៊ីវិលនិងរាជរដ្ឋាភិបាល ទី២ កាត់បន្ថយចំនួនការិយាធិបតេយ្យក្នុងដំណើរការចុះអនុសារណៈយោគយល់រវាងរដ្ឋាភិបាលនិងសង្គមស៊ីវិល និង ទី៣ ប្រមូលព័ត៌មានបន្ថែមពីសង្គមស៊ីវិលទាក់ទងនឹងដំណើរការចុះអនុសារណៈយោគយល់រវាងរដ្ឋាភិបាលនិងសង្គមស៊ីវិល ដើម្បីស្វែងរកដំណោះស្រាយ។

វាគ្មិនចំនួន ៤នាក់មកពីស្ថាប័នផ្សេងៗគ្នាបានចូលរួមក្នុងកិច្ចពិភាក្សាដ៏មានអត្ថន័យនេះ រួមមាន៖

- **ឯកឧត្តម ម៉ក់ វ៉ាន់** រដ្ឋលេខាធិការ នៃក្រសួងអប់រំ យុវជន និង កីឡា
- **ឯកឧត្តម គោ សឿត** រដ្ឋលេខាធិការ នៃក្រសួងសង្គមកិច្ច និង អតីតយុទ្ធជន
- **លោកវេជ្ជបណ្ឌិត ស៊ឹម គឹមសាន** ប្រធាននាយកដ្ឋាន ទំនាក់ទំនង និង គៀងគរប្រភពធនធាន នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- **លោកវេជ្ជបណ្ឌិត ហ៊ី សុមៀវ** ប្រធានកម្មវិធីអេដស៍ នៃក្រសួងមហាផ្ទៃ

បន្ទាប់ពីជម្រាបអំពីកម្មវិធី និងគោលបំណងរួចមក លោក ទឹម វ៉ា បានបង្ហាញពីដំណើរការចុះអនុសារណៈយោគយល់រវាងរដ្ឋាភិបាលនិងសង្គមស៊ីវិល ដោយបញ្ជាក់ផងដែរនូវបញ្ហាមិនប្រក្រតីនានា ដែលកើតឡើងក្នុងកំឡុងពេលចុះអនុសារណៈយោគយល់រវាងរដ្ឋាភិបាលនិងសង្គមស៊ីវិល។

ក្នុងនាមសង្គមស៊ីវិល លោក ទឹម វ៉ា បានលើកឡើងជាសង្ខេបនូវភាពយឺតយ៉ាវក្នុងការអនុម័តលើអនុសារណៈយោគយល់រវាងរដ្ឋាភិបាលនិងសង្គមស៊ីវិល ការអនុវត្តនូវដំណើរការការងារសហការជាផ្លូវច្បាប់បានផ្តល់ផលប៉ះពាល់អវិជ្ជមានដោយសារតែភាពស្មុគស្មាញនៃប្រព័ន្ធរដ្ឋបាល ចំនួននៃអនុសារណៈយោគយល់រវាងរដ្ឋាភិបាលនិងសង្គមស៊ីវិលមានចំនួនច្រើន ដោយចំនួននេះមិនរាប់បញ្ចូលនូវការធ្វើលិខិតព្រមព្រៀង រឺ លិខិតគាំទ្រជាមួយមន្ទីរនានាដែលស្ថិតនៅក្នុងស្ថាប័នតែមួយ។

ឆ្លើយតបទៅនិងភាពស្មុគស្មាញនេះ សង្គមស៊ីវិលបានធ្វើការស្នើរសុំឲ្យមានយន្តការ **ច្រកចូល ចេញតែមួយ** ដោយ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជាអ្នកសម្របសម្រួល ក្នុងចំណោមស្ថាប័នរដ្ឋ ក្នុងដំណើរការចុះអនុសារណៈយោគយល់រវាងរដ្ឋាភិបាលនិងសង្គមស៊ីវិល ចំណែក គសអ ត្រូវសម្របសម្រួលក្នុងចំណោមសង្គមស៊ីវិលរៀបចំឯកសារពាក់ព័ន្ធក្នុងការធ្វើអនុសារណៈយោគយល់រវាងរដ្ឋាភិបាលនិងសង្គមស៊ីវិល។ លោកនាយក

ប្រតិបត្តិ គសអ បានលើកទឹកចិត្តដល់អ្នកចូលរួមឲ្យមានការចូលរួមនិងលើកឡើងនូវអ្វីដែលជាបញ្ហាក្នុងដំណើរការចុះអនុសារណៈយោគយល់រវាងរដ្ឋាភិបាលនិងសង្គមស៊ីវិល។

លោកវេជ្ជបណ្ឌិត ស៊ឹម គឹមសាន ប្រធាននាយកដ្ឋាន ទំនាក់ទំនង និងគៀងគរប្រភពធនធាន នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានបង្ហាញពីសារៈសំខាន់នៃវេទិកាពិភាក្សា និងមានសុទិដ្ឋិនិយមចំពោះការប្រយុទ្ធទប់ស្កាត់ជំងឺអេដស៍។ លោកវេជ្ជបណ្ឌិត បានបន្តទៀតថានេះជាការចូលរួមដ៏វិសេសវិសាលមួយខណៈដែលវិបត្តិសេដ្ឋកិច្ចពិភពលោកកំពុងតែបន្ត វាជាហេតុផលមួយបណ្ដាលឲ្យមានការកាត់បន្ថយមូលនិធិ ហើយបណ្ដារអ្នកពាក់ព័ន្ធទាំងអស់ត្រូវតែយកចិត្តទុកដាក់លើការព្រមព្រៀងដែលពួកគេបានបង្កើតឡើង ដែលជាផ្នែកមួយនៃផែនការយុទ្ធសាស្រ្តជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅនឹងការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ២០១១-២០១៥។ លោកបានមាន ប្រសាសន៍ថា កិច្ចការងារជំងឺអេដស៍ នៅក្នុងបុព្វបទប្រទេសកម្ពុជា យើងនឹងអាចសំរេចបានលទ្ធផលយ៉ាងត្រចះត្រចង់ទៅបាន ប្រសិនបើយុទ្ធសាស្រ្តនៃការចូលរួមជាពហុវិស័យ និងទទួលលទ្ធផល ដោយមានការសហការដ៏ល្អរបស់ពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។ លោកបានបញ្ជាក់ថា វាជាការចាំបាច់និងមានសារៈសំខាន់ណាស់ចំពោះការសហការដ៏ស្និទ្ធស្នាលគ្នារវាងអាជ្ញាធរជាតិប្រយុទ្ធ នឹងជំងឺអេដស៍ និង គសអ។ ដើម្បីកាត់បន្ថយ ការជាន់តំបន់ និង ក្រុមគោលដៅ លោកវេជ្ជបណ្ឌិត ស៊ឹម គឹមសាន បានស្នើរឡើងថា គម្រោងផែនការទាំងអស់គួរតែដាក់ឲ្យមាន ប្រព័ន្ធតាមដាននិងវាយតម្លៃ និងប្រព័ន្ធរបាយការណ៍រួមមួយ។

ឯកឧត្តម ម៉ក់ វ៉ាន់ រដ្ឋលេខាធិការ នៃក្រសួងអប់រំ យុវជន និងកីឡាយល់ស្របទៅនឹងទស្សនៈរបស់លោកវេជ្ជបណ្ឌិត ស៊ឹម គឹមសាន។ ឯកឧត្តម បានរំលឹកដល់ភាពជ័យជំនះនៃការឆ្លើយតបទៅនឹងមេរាគអេដស៍ និងជំងឺអេដស៍នៅក្នុងប្រទេសកម្ពុជាទៅដល់អង្គពិធីទាំងមូល។ ឯកឧត្តម ម៉ក់ វ៉ាន់ បានមានប្រសាសន៍បន្តថា ថ្វីបើគម្រោងនៃក្របខណ្ឌនីតិបញ្ញាត្តិថ្មីនេះ បានផ្ដល់ហានិភ័យសម្រាប់រលកទីពីរ ដូច្នេះវាទាមទារឲ្យមានការចូលរួម ពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់ ហើយពួកគេគួរតែពង្រឹងស្មារតីក្នុងការកែតម្រូវឡើងវិញនូវបទអន្តរាគមន៍របស់ពួកគេឲ្យបានសមរម្យ ស្របតាមនិយាមនៃ ភាពជាម្ចាស់ សុខដុមនីយកម្ម ភាពស្របគ្នា ភាពតម្រង់ទិសលើលទ្ធផល និងទស្សនៈពហុវិស័យ។

ទាក់ទងទៅនិងដំណើរការចុះអនុសារណៈយោគយល់រវាងរដ្ឋាភិបាលនិងសង្គមស៊ីវិល ថ្មីៗនេះ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតនូវគណៈកម្មាធិការអន្តរនាយកដ្ឋានតំណាងឲ្យពិធីសារដ៏ច្រើន និងជាគំរូមួយ នៃកិច្ចសហប្រតិបត្តិការណ៍ចុះអនុសារណៈយោគយល់នេះ ហើយឯកឧត្តមក៏បានស្នើរសុំផងដែរឲ្យអ្នកស្នើរសុំគោរពនូវគោលការណ៍នេះ។ សម្រាប់កិច្ចសហការអន្តររដ្ឋាភិបាល ជាតម្រូវការចាំបាច់ត្រូវមានអនុសារណៈយោគយល់រវាងរដ្ឋាភិបាលនិងសង្គមស៊ីវិល រវាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និង អង្គការអន្តរជាតិនោះ។

បន្ទាប់ពីចំណាប់អារម្មណ៍ និងការបង្ហាញពីដំណើរការចុះអនុសារណៈដោយសង្ខេបតាមក្រសួងនីមួយៗ រួចមកតំណាងសង្គមស៊ីវិលបានលើកឡើងនូវការព្រួយបារម្ភរបស់ពួកគេទាក់ទង និងបញ្ហាទាំងនេះ ទៅតំណាងក្រសួងនានា។ បញ្ហាដែលពួកគេជួបប្រទះញឹកញាប់ជាងគេគឺ ចំនួននៃអនុសារណៈច្រើន ហើយការបំពេញទម្រង់មានភាពស្មុគស្មាញពិបាកយល់។ ប្រព័ន្ធបច្ចុប្បន្ន បានតម្រូវឲ្យអ្នកស្នើរសុំធ្វើការកំណត់នូវប្រភេទកម្មវិធីទាំងខ្សែបណ្តោយនិងខ្សែទទឹង ទៅតាមវិស័យ និងតាមតំបន់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងដាក់បន្ទុកធ្ងន់ធ្ងរមកលើអ្នកស្នើរសុំចុះអនុសារណៈ។ ការមិនមានគោលការណ៍ណែនាំអំពីការបែងចែកកម្មវិធីជាបច្ច័យនាំមកនូវការភ័ន្តច្រលំនិងត្រួតគ្នាក្នុងដំណើរការនេះ។ តម្រូវការចាំបាច់សម្រាប់ដំណើរការនេះគឺ ការមានតួអង្គសម្របសម្រួលមួយដែលធ្វើការយ៉ាងប្រាកដ ដើម្បីបង្កើតយន្តការដែលមានប្រសិទ្ធភាព សម្រាប់ដំណើរការចុះអនុសារណៈយោគយល់នេះ។ អ្នកដែលបានដាក់ពាក្យស្នើរសុំធ្វើអនុសារណៈយោគយល់បានជួបប្រទះបញ្ហាផងដែរទាក់ទងជាមួយមន្ត្រីដែលធ្វើការនៅតាមការិយាល័យនីមួយៗដូចជា ទំនាក់ទំនងមិនចំអ្នកទទួលខុសត្រូវចំណាយពេលវេលាច្រើន មិនប្រាប់ពីកន្លែងដាក់លាក់ដែលត្រូវដាក់ពាក្យស្នើរសុំ។

វាគួតែមានការចាត់ឲ្យមានអ្នកតំណាង ទទួលខុសត្រូវច្បាស់លាស់លើកិច្ចការរៀបចំអនុសារណៈយោគយល់គាំទ្រដល់សង្គមស៊ីវិលនិងជួយដោះស្រាយបញ្ហាឲ្យបានឆាប់រហ័សនិងមានប្រសិទ្ធភាពនៅពេលដែលចាំបាច់។ ជាងនេះទៅទៀត បុគ្គលិករបស់អង្គការដៃគូរ គួរតែទទួលបាននូវការណែនាំពីរបៀបបំពេញទម្រង់បែបបទនៃអនុសារណៈយោគយល់ និង តម្រូវការចាំបាច់ផ្សេងៗសម្រាប់ ដូចជាឯកសារយោងជាដើម។ អ្នកផ្តល់ការណែនាំគួរតែផ្តល់ព័ត៌មានច្បាស់លាស់ និងអាចទំនាក់ទំនង់បានគ្រប់ពេល។ អង្គវេទិកាបានស្នើរឡើងថាប្រព័ន្ធទាំងនេះគឺជាវិធីតែមួយគត់ដើម្បីធានានូវដំណើរការនៃការស្នើសុំ និងបញ្ជូនទំរង់បែបបទនៃអនុសារណៈយោគយល់ ប្រកបដោយគុណភាព ហើយអនុសារណៈ និងប្រព័ន្ធបញ្ជូនដែលធ្លាប់មានពីមុនមក ជាមូលហេតុនាំអោយមានការបង្កើតប្រព័ន្ធថ្មីដែលមានភាពប្រសើរជាងមុន ។

ឆ្លើយតបទៅនិងផលលំបាកដែលលើកឡើងដោយសង្គមស៊ីវិល វាគ្មិនកិត្តិយសទាំងអស់បាន មានទស្សនៈស្របគ្នាថា ភាពខុសគ្នារវាងអនុសារណៈយោគយល់គ្នានៅក្នុងកម្មវិធីមេរោគអេដស៍ និងជំងឺអេដស៍នេះ គឺបណ្តាលមកពីអេដស៍គឺជាបញ្ហាដែលត្រូវឆ្លើយតបជាពហុវិស័យ។ វេទិកាក៏បានលើកឡើងផង ដែរថាវិធីតែមួយគត់ដែលអាចធានាបាននូវនិរន្តភាពរបស់អនុសារណៈយោគយល់គ្នានេះគឺការធ្វើសមាហរណកម្មក្រសួងដែលពាក់ព័ន្ធនិងទំនួលខុសត្រូវរបស់ពួកគេ នៅក្នុងដំណើរការនៃការធ្វើអនុសារណៈយោគយល់គ្នានេះ។

មានការស្នើសុំអោយមានការកាត់បន្ថយបន្ទុកចំពោះរចនាសម្ព័ន្ធបច្ចុប្បន្នដែលដាក់បន្ទុកលើអ្នកពាក់ព័ន្ធនីមួយៗ និង ទំនាក់ទំនងដ៏រឹងមាំរវាងភ្នាក់ងារដែលចូលរួមទាំងអស់ នៅក្នុងដំណើរការបង្កើតអនុសារណៈយោគយល់គ្នានេះ។ គួឲ្យកត់សម្គាល់ដែរថា មានតែការបន្តសហការគ្នារវាង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និង គសអ ទេ ដែលអាចជម្រុញការងារនេះឲ្យមានប្រសិទ្ធភាព ទោះបីជា យើងធ្លាប់មានបទពិសោធន៍ នៃភាពខុសទម្រង់គ្នាក្នុងការចុះអនុសារណៈយោគយល់រវាងដៃគូអនុវត្តការងារដែលមិនអាចត្រូវបានកំណត់សម្រាប់ស្ថាប័នតែមួយ។

ឆ្លើយតបទៅនឹងការព្រួយបារម្ភដែលលើកឡើង ពីភាពយឺតយ៉ាវ ក្នុងដំណើរការចុះអនុសារណៈយោគយល់នេះ យើងគួរដាក់ចេញនូវដំណើរការមួយដែលធានាថា មានការប្រសើរឡើងក្នុងការអនុញ្ញាតិជាផ្លូវច្បាប់ ប្រសិនបើពួកគេបានបំពេញទម្រង់ត្រឹមត្រូវ នូវទីកន្លែងអនុវត្តគម្រោង ប្រភេទគម្រោង មូលហេតុនៃការអនុវត្តគម្រោង និងរបៀបនៃការអនុវត្តគម្រោង ឲ្យបានច្បាស់ដាក់ទៅក្រសួងពាក់ព័ន្ធ។ ប្រសិនបើដំណើរការយឺតជាង២ខែ អ្នកដាក់ពាក្យសុំមានសិទ្ធិប្តឹងបាន។ យើងចាប់ផ្តើមធ្វើការត្រួតពិនិត្យលើយន្តការទាំងនេះ ថាតើយន្តការទាំងនេះបានចាប់ផ្តើមរៀបចំហើយរឺនៅ ហើយថាតើវាសមស្របជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ចំណែក គសអ នឹងចូលរួមយ៉ាងសកម្មក្នុងការពាំនាំការព្រួយបារម្ភដែលលើកឡើងដោយសង្គមស៊ីវិល។

លោក ទឹម វ៉ា ថ្លែងអំណរគុណដល់អ្នកចូលរួមដែលបានចូលរួមក្នុងកិច្ចពិភាក្សា និងធ្វើការសរុបយ៉ាងសង្ខេបនូវលទ្ធផលនៃកិច្ចពិភាក្សាស្តីអំពី ការចុះអនុសារណៈយោគយល់រវាងរដ្ឋាភិបាល និង សង្គមស៊ីវិល ដើម្បីឆ្លើយតបទៅនិងបញ្ហាអេដស៍នៅកម្ពុជា។

### ៣. លទ្ធផលនៃកិច្ចប្រជុំ

វេទិកាពិភាក្សាស្តីពីអនុសារណៈយោគយល់រវាងរដ្ឋាភិបាលនិងសង្គមស៊ីវិល ដើម្បីឆ្លើយតបទៅនិងបញ្ហាអេដស៍នៅកម្ពុជា បានសម្រេចគ្នាដូចខាងក្រោម៖

- បង្កើតនូវ**យន្តការច្រកចូល ចេញតែមួយ** សម្រាប់ការចុះអនុសារណៈយោគយល់រវាងរដ្ឋាភិបាលនិងសង្គមស៊ីវិល ដោយ គសអ ជាអ្នកសម្របសម្រួល រៀបចំឯកសារក្នុងចំណោមសង្គមស៊ីវិល រួចដាក់ជូនទៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នឹងបង្កើតទម្រង់បែបបទសម្រាប់ចុះអនុសារណៈយោគយល់តែមួយ និងសម្របសម្រួល ជាមួយក្រសួងពាក់ព័ន្ធ ដើម្បីឲ្យមានការចុះហត្ថលេខាក្នុងថ្ងៃតែមួយ។ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នឹងប្រើប្រាស់ទម្រង់តែមួយសម្រាប់មន្ទីរពាក់ព័ន្ធ និងបង្កើតឲ្យមានគោលការណ៍ណែនាំមួយសម្រាប់ការចុះអនុសារណៈយោគយល់រវាងរដ្ឋាភិបាលនិងសង្គមស៊ីវិល។
- បង្កើតឲ្យមានកិច្ចប្រជុំណែនាំស្តីពីគោលការណ៍ណែនាំនៃ ដំណើរការនៃការចុះអនុសារណៈយោគយល់រវាងរដ្ឋាភិបាលនិងសង្គមស៊ីវិល ជាមួយអ្នកពាក់ព័ន្ធ។